**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ ..២៨៧៥.. PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការងារឈ្នួលពលកម្ម បង្វែរខ្សែបណ្តាញអាកាស LV ឆ្លងផ្លូវ មកជាខ្សែកាបកប់ដីតាមដួរផ្លូវសំខាន់ៗ ក្នុងរាជធានីភ្នំពេញ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាលក្ខណៈអន្តរជាតិ ដើម្បីជ្រើសរើសអ្នកទទួលការងារឈ្នួលពលកម្ម បង្វែរខ្សែបណ្តាញអាកាស LV ឆ្លងផ្លូវ មកជាខ្សែកាបកប់ដីតាមដួរផ្លូវសំខាន់ៗ ក្នុងរាជធានីភ្នំពេញ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង ១៦:00 ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃច័ន្ទ ១៥កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ទ៉ែត_ស៊ុខន

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ